ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី១ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១ សម្រាប់ឆ្នាំ២០១៨ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តៃង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-បទបង្ហាញសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៧

-បទបង្ហាញពីការរៀបចំថវិកាប្រចាំឆ្នាំ២០១៨ របស់សមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តៃង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**ប្រធានបទទី១**: បទបង្ហាញពីសេចក្តីសម្រេចចិត្ត កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៧ ដោយ **ឯកឧត្តមវេជ្ជ. រស់ សីលវ៉ាត់** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយឯកឧត្តមបានធ្វើការពន្យល់បកស្រាយនូវចំណុចនីមួយៗដូចខាងក្រោម៖

១. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបន្តធ្វើផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ ស្របតាមអាណត្តិរបស់ខ្លួនដាក់ក្នុងផែនការថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្តនីមួយៗ។

២. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងមហាផ្ទៃ (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអគ្គស្នងការដ្ឋាននគរបាលជាតិ) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ត្រូវបង្កើន**សកម្មភាពអប់រំការបង្ការ**ការឆ្លងមេរោគអេដស៍ ការជួយ**ស្វែងរកករណីអេដស៍ថ្មី** ការ**បញ្ជូនអ្នកផ្ទុកមេរោគអេដស៍ទៅសេវាថែទាំព្យាបាល** **ការសម្របសម្រួលបង្កបរិយាកាសអំណោយផល**ដូចចែងក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព **និងការផ្តល់កញ្ចប់គាំទ្រសង្គម** ដែលដាក់បញ្ចូលក្នុងផែនការវិនិយោគ និងផែនការអភិវឌ្ឍឃុំសង្កាត់។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងផែនការ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត អង្គការសង្គមស៊ីវិលពាក់ព័ន្ធ និងបណ្ដាញអ្នកផ្ទុកមេរោគអេដស៍ ត្រូវបន្តសហការរួមគ្នាពង្រីកការផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដល់អ្នកផ្ទុកមេរោគអេដស៍ក្រីក្រ។

៤. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបន្តជំរុញការប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមសហគ្រាសគ្រឹះស្ថាននានា ដោយដាក់ឱ្យអនុវត្តតាមប្រកាសលេខ០៨៦ ក.ក.ប.វ/ប្រ.ក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាសគ្រឹះស្ថាន និងការបង្ការ ទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ និងប្រកាសលេខ១៩៤ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារ នៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត។

៥. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រសួងទេសចរណ៍ ត្រូវបន្តសហការជំរុញការប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងវិស័យទេសចរណ៍។

៦. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការពារជាតិ ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ត្រូវបន្តបង្កើនការផ្សព្វផ្សាយ**ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់**ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ **ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** និង**គោលនយោបាយភូមិឃុំមានសុវត្ថិភាព** ដល់មហាជនទូទៅ និងអ្នកអនុវត្តច្បាប់។

៧. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តជាប់ព្រំដែនកម្ពុជាថៃ ខេត្តកោះកុង បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន ពោធិ៍សាត់ និងព្រះវិហារ ត្រូវបង្កើនការអប់រំបង្ការមេរោគអេដស៍ ក្នុងចំណោមប្រជាជនចំណាកស្រុក។

៨. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងស្ថាប័នពាក់ព័ន្ធ ត្រូវបញ្ចប់ការផលិត និងចាប់ផ្តើមអនុវត្តគោលការណ៍ណែនាំជាតិ ស្តីពីការប្រុងប្រយ័ត្នជាសកលចំពោះការចម្លងមេរោគអេដស៍ នៅកន្លែងផ្តល់សេវាវះកាត់កែសម្ផស្ស ធ្វើធ្មេញ អប់សព សាក់ ឬការងារដទៃទៀត។

៩. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមការងារជាតិចីរភាពនៃការឆ្លើយតបនឹងជំងឺអេដស៍ ត្រូវរិះរកមធ្យោបាយផ្តល់ថវិកាគាំទ្រដល់ការអនុវត្តផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដែលស្នើឡើងដោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត៕

ក្រោយបង្ហាញចប់ឯកឧត្តមប្រធានអង្គប្រជុំ បានអនុញ្ញាតិឱ្យមានការចូលរួមយោបល់ដូចខាងក្រោម៖

**តំណាងអង្គការ KHANA:** ត្រង់ចំណុចទី៤ តើអាចឱ្យមានថវិកាសម្រាប់អនុវត្តសកម្មភាពដូចចំណុចទី១បានដែរឬទេ? ព្រោះចំណុចទី១ មានថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាព។

**ឯកឧត្តមវេជ្ជ. រស់ សីលវ៉ាត់:** តាមប្រកាសលេខ៨៦ និងប្រកាសលេខ១៩៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារ នៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត បានបញ្ជាក់ច្បាស់ គឺក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកអនុវត្តសកម្មភាព ហើយបើមិនបានបង្កើតគណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍ នោះក្រសួងជាអ្នកវាយតម្លៃឱ្យពិន្ទុទៅតាមស្ថានភាពជាក់ស្តែង។ កន្លងមករោងចក្រ សហគ្រាស ជាអ្នកផ្តល់ទីកន្លែង ហើយក្រុមការងារ ឬអង្គការនានា ជាអ្នកចូលទៅធ្វើការអប់រំពីបញ្ហាមេរោគអេដស៍។ ចំពោះស្ថានភាព

បច្ចុប្បន្នដែលថវិកាជំនួយកំពុងថយចុះ តម្រូវឱ្យក្រសួងធ្វើចលនាប្រភពធនធាន ឬចូលរួមសហការជាមួយស្ថាប័នជំនាញសម្រាប់ធ្វើការអប់រំពីបញ្ហាអេដស៍នេះ។

**ឯកឧត្តមប្រធានអង្គប្រជុំ:** កន្លងមកមានពេងចក្រ សហគ្រាស ៤-៥ បានមកទាក់ទងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីបានសម្ភារមួយចំនួនទៅធ្វើការអប់រំផ្សព្វផ្សាយ និងជួយចុះទៅអប់រំផ្ទាល់នៅទីនោះ។

**តំណាងអង្គការ FHI 360:** បានជម្រាបជូនថាអង្គការ CWPD មានកម្មវិធីធ្វើទៅលើពេងចក្រ (ដោយមានថវិកាជំនួយ) តែមានការលំបាកទៅលើសេវាកម្សាន្តសប្បាយ ជាពិសេសទៅលើស្ត្រីឯករាជ្យដែលពិបាកធ្វើការអប់រំ និងធ្វើតេស្តឈាម។

**ឯកឧត្តមប្រធានអង្គប្រជុំ:** ស្នើឱ្យអង្គការ FHI 360 និងអង្គការ CWPD រួមជាមួយនឹងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទៅជួបជាមួយក្រសួងទេសចរណ៍ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

**ឯកឧត្តមវេជ្ជ. រស់ សីលវ៉ាត់:** បានបន្ថែមថា៖

- ✓ ក្នុងប្រកាសលេខ១៩៤ ដែលតម្រូវអោយក្រុមអង្គការមិនមែនរដ្ឋាភិបាល រៀបចំជួយដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ✓ ធ្វើការសិក្សាជាមួយក្រសួងព័ត៌មាន ដោយក្រសួងអាចពិចារណាថានេះជាឱកាសដែលអាចរកថវិកាជាតិមកផលិតជាស្ពតខ្លីៗសម្រាប់ចាក់ផ្សាយអប់រំតាមវិទ្យុដល់ស្ត្រីឯករាជ្យ(ស្ត្រីកាលីប) ដែលអង្គការមិនមែនរដ្ឋាភិបាលពិបាកជួប។

**តំណាងអង្គការ HACC:** ត្រង់ចំណុចទី៧ តើយើងអាចធ្វើនៅខេត្តស្វាយរៀងបានឬទេ ព្រោះវាក៏ជាចំណុចក្តៅមួយដែរ។

**ឯកឧត្តមវេជ្ជ. រស់ សីលវ៉ាត់:** បានលើកឡើងថា មូលហេតុដែលពុំបានបញ្ជាក់នៅក្នុងចំណុចនោះដោយសារប្រជាជនភាគច្រើនចល័តទៅទិសខាងលិច ច្រើនជាងទៅទិសខាងកើត ហើយពុំមានការសិក្សាណាមួយពីបញ្ហានេះនៅឡើយ។

**តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ:** ពីឆ្នាំ២០១៨-២០២០ គឺមានថវិកាជំនួយពីប្រភពតែមួយគត់គឺមូលនិធិសកល ដែលធ្វើលើបីកម្មវិធី គឺគ្រុនចាញ់ របេង អេដស៍ ក្នុងវង្ងង់ថវិកា ១០០លានដុល្លារអាមេរិក ហើយចំពោះកម្មវិធីអេដស៍ក្នុងវង្ងង់ថវិកា៤០លានដុល្លារអាមេរិកក្នុងរយៈពេល៣ឆ្នាំ។ តើថវិកាជាតិអាចជួយដល់អង្គការសង្គមស៊ីវិលបានទេ បើមិនបាននៅពេលនេះ គឺអាចរយៈពេល៣ឆ្នាំទៀត នៅពេលដែលថវិកាជំនួយត្រូវបញ្ចប់ ព្រោះអង្គការសង្គមស៊ីវិលអាចបំពេញចន្លោះប្រហោងដែលរដ្ឋាភិបាលមិនបានធ្វើ។

**ឯកឧត្តមប្រធានអង្គប្រជុំ:** ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បាននឹងកំពុងរៀបចំក្រុមការងារសម្រាប់ពិនិត្យមើលលើបញ្ហានេះហើយ។

**ប្រធានបទទី២៖** បទបង្ហាញពីការរៀបចំថវិកាប្រចាំឆ្នាំ២០១៨ របស់សមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បង្ហាញជូនដោយ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយឯកឧត្តមបានធ្វើការបកស្រាយដូចខាងក្រោម៖

- ✓ ទិសដៅនៃកំណែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៣-២០២០ ផ្លាស់ប្តូរពីប្រព័ន្ធថវិកាលើជាតុចូល មជ្ឈការទៅជាជាតុចេញ វិសហមជ្ឈការ និងវិមជ្ឈការ៖

  ១.ការរៀបចំ: ត្រូវផ្អែកលើគោលនយោបាយ កម្មវិធី និងសូចនាករដែលមានក្របខ័ណ្ឌគតិយុត្តិ និងយន្តការច្បាស់លាស់ក្នុងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងអាចវាស់វែងលទ្ធផលដើម្បីធានាវិន័យថវិកា

(តុល្យភាព/និរន្តរភាព) ប្រសិទ្ធភាពវិភាជ (វិភាជចំគោលដៅអាទិភាព) និងប្រសិទ្ធភាពបច្ចេកទេស (ប្រកបដោយភាពស័ក្តិសិទ្ធិ) ព្រមទាំងគោលការណ៍ទាំង១១ នៃថវិកា។

២.ការអនុម័តៈ ត្រូវផ្លាស់ប្តូរពីប្រភេទ ជំពូក ទៅជាគោលនយោបាយ កម្មវិធី និងសូចនាករ

៣.ការអនុវត្តថវិកាៈ ជានាឱ្យមានការអនុវត្តថវិកាប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ពិសេសគឺការផ្លាស់ប្តូរពីការត្រួតពិនិត្យលើធាតុចូល ទៅជាការតាមដានវាយតម្លៃលើធាតុចេញ។

៤.ការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មៈ ធានាឱ្យមានតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីអាចអនុវត្តក្របខ័ណ្ឌ និងយន្តការតាមដាន វាយតម្លៃលទ្ធផល និងការគ្រប់គ្រងផ្តោតលើធាតុចេញ (វិសហមជ្ឈការ/វិមជ្ឈការ) ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព។

- ✓ ក្របខ័ណ្ឌគោលនយោបាយថវិកាឆ្នាំ២០១៨: ថវិកាឆ្នាំ២០១៨ ត្រូវបានប្រសិទ្ធនាមថាជា"ថវិកាយុទ្ធសាស្ត្រនៃការប្រមូលផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោកដែលកាន់តែមានសភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព ស្ថេរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវត្តឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាពតទៅមុខឥតឈប់ឈរ ក្នុងនីតិកាលបន្តបន្ទាប់ទៀត"។
- ✓ ទិសដៅការងារសំខាន់ៗសម្រាប់អនុវត្តបន្តៈ

-ត្រៀមរៀបចំថវិកាឆ្នាំ២០១៩ (១. ខែមីនា ដល់ខែឧសភាៈ រៀបចំផែនការយុទ្ធសាស្ត្រថវិកា ២. ខែមិថុនា ដល់ខែកញ្ញាៈ ការរៀបចំកញ្ចប់ថវិកា ៣. ខែតុលា ដល់ខែធ្នូៈ ការអនុម័តថវិកា)។

-កំណត់សកម្មភាពអាទិភាព និងសូចនាករនៃការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ស្របតាមអាណត្តិការងាររបស់ក្រសួង ស្ថាប័ន និងស្របតាមយុទ្ធសាស្ត្រ NSP IV។

-បន្តការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពង្រីកការគាំទ្រផ្តល់ថវិកាសម្រាប់អនុវត្តសកម្មភាពដែលបានកំណត់ខាងលើ តាមរយៈការបង្ហាញភស្តុតាងរឹងមាំតាមបែបវិទ្យាសាស្ត្រ។

-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងត្រៀមខ្លួនជាស្រេចសម្រាប់ផ្តល់ការប្រឹក្សាបច្ចេកទេស។

ក្រោយបង្ហាញចប់ឯកឧត្តមប្រធានអង្គប្រជុំ បានមានប្រសាសន៍ថា ក្រសួងសាធារណៈការ និងដឹកជញ្ជូន បានទទួលថវិកាជាតិសម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ដល់កម្មករធ្វើផ្លូវ និងប្រជាពលរដ្ឋនៅតាមអមផ្លូវ។

**តំណាងក្រសួងទេសចរណ៍:** ក្រសួងទេសចរណ៍តែងតែចូលរួមក្នុងការលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ និងសំណូមពរដល់អង្គការសង្គមស៊ីវិលធ្វើលិខិតមកក្រសួង ដើម្បីធ្វើការសម្របសម្រួលទៅលើវត្ថុបំណងរបស់លោក លោកស្រី និងសូមអរគុណចំពោះការចូលរួមរបស់អង្គការនានា ជាពិសេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានផ្តល់ថវិកា និងបច្ចេកទេសក្នុងការអនុវត្តសកម្មភាពកន្លងមក។

**តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:** បច្ចុប្បន្នយើងប្រើថវិកាកម្មវិធី។ កន្លងមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំសូចនាករបានច្បាស់លាស់ និងមានរបាយការណ៍បានត្រឹមត្រូវ។ ពេលការពារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានការតវ៉ា លំបាកខ្លាំង សូមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បង្ហាញសូចនាករ ដោយប្រមូលផ្តុំគ្រប់ក្រសួង ស្ថាប័នតែម្តង ដើម្បីងាយស្រួលក្នុងការការពារ។

**ឯកឧត្តម ឈឹម យិនដារ៉េត:** កន្លងមកយើងបានរៀបចំដូចការលើកឡើងរបស់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែវាបង្កជាបញ្ហាប៉ោងថវិកាជាមួយក្រសួងសុខាភិបាល ជាហេតុធ្វើឱ្យក្រសួង ស្ថាប័ន ធ្វើគម្រោងផែនការរៀងៗខ្លួន។ ចំពោះបញ្ហានេះអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងធ្វើការសាកល្បងទៀត ដោយធ្វើសៀវភៅមួយបង្ហាញលម្អិតដោយឡែកមួយសម្រាប់ការពារក្រសួង ស្ថាប័នទាំងនោះ។

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបជូនដល់សមាជិក-សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨** ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង២០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**ឧបសម្ព័ន្ធ:**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨

**បានឃើញ និងឯកភាព**
**អគ្គលេខាធិការ**

**វេជ្ជ.តែង គន្ធី**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រកពធនធាន**

**អ្នកធ្វើរបាយការណ៍**

20-2-18